អ៊ីមែល: advertising@phnompenhpost.com
www.postkhmer.com/special-report

# ប៉ុស្តិ៍ សិក្សាអប់រំ

អ៊ីមែល: advertising@phnompenhpost.com
www.postkhmer.com/special-report

ថ្ងៃសុក្រ ទី១៧ ខែកក្កដា ឆ្នាំ២០២០ // WWW.POSTKHMER.COM/SPECIAL-REPORT



# ស្វាគមន៍ការវិលត្រឡប់មកសាលារៀនសាជាថ្មី

រូបថត ហេង ជីវ័ន

# ការអប់រំនៅពេលអនាគតនឹងផ្តោតកាន់តែសំខាន់ទៅលើជំនាញនិងទេពកោសល្យរបស់និស្សិត

**អ្នកផ្តល់ការអប់រំ និងជាសហគ្រិនជនជាតិម៉ាឡេស៊ីដ៏ល្បីល្បាញ លោក Lim Kok Wing បានចែករំលែកចក្ខុវិស័យដ៏មានតម្លៃរបស់លោក អំពីអនាគតនៃវិស័យអប់រំ នៅក្នុងបទសម្ភាសតាមអ៊ីមែលជាមួយកាសែតភ្នំពេញប៉ុស្តិ៍។**



លោក Lim Kok Wing ស្ថាបនិក និងជាប្រធានសាកលវិទ្យាល័យ លីមកុកវីង ដ៏ល្បីល្បាញ។

**Q ការច្នៃប្រឌិតត្រូវបានចាត់ទុកថាជាកត្តាជំរុញដ៏សំខាន់សម្រាប់ការអប់រំនៅសតវត្សរ៍ទី២១នេះ។ តើលោកយល់ស្របនឹងទស្សនៈនេះដែរឬទេ?**

ទស្សនៈដំបូងនៃពាក្យច្នៃប្រឌិតត្រូវតែយល់ឱ្យបានច្បាស់ ដើម្បីដឹងថាតើហេតុអ្វីបានជាវាក្លាយជាកត្តាជំរុញដ៏សំខាន់សម្រាប់ការអប់រំនៅសតវត្សរ៍ទី២១នេះ។ ការច្នៃប្រឌិតតែងតែជាធាតុមួយនៃការលូតលាស់របស់មនុស្ស ដែលបានរួមចំណែកដល់របៀបដែលយើងបានរីកចម្រើននៅលើភពផែនដីនេះ។ ការច្នៃប្រឌិតគឺជាទិដ្ឋភាពធម្មជាតិរបស់មនុស្សដែលជំរុញយើងឱ្យអភិវឌ្ឍរបៀបនៃការអនុវត្តបច្ចុប្បន្ន។ ដូច្នេះយើងបានបង្កើតនិងច្នៃប្រឌិតជាបន្តបន្ទាប់។

សព្វថ្ងៃយើងបានឈានដល់ចំណុចមួយដែលការរីកចម្រើនរបស់យើងបានកើនឡើងយ៉ាងឆាប់រហ័ស។ រាល់ការជឿនលឿនផ្នែកបច្ចេកវិទ្យា បានពន្លឿនដល់ការផ្លាស់ប្តូរបន្ទាប់ ដែលយើងបានឃើញនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង។

អ្វីដែលធ្លាប់ចំណាយពេលរាប់ខែត្រូវបានកាត់បន្ថយមកត្រឹមប៉ុន្មានសប្តាហ៍ ហើយបច្ចុប្បន្ន អាចនៅសល់តែប៉ុន្មានវិនាទីប៉ុណ្ណោះ។ ពេលនេះយើងកំពុងឈានដល់ពេលវេលានៃការផ្លាស់ប្តូរដ៏ធំនិងឆាប់រហ័ស ជាមួយនឹងការច្នៃប្រឌិតថ្មីក្នុងការប្រើប្រាស់បញ្ញានិម្មិត ភាពជឿនលឿននៃប្រព័ន្ធអ៊ីនធឺណិត និងវិទ្យាសាស្ត្រដែលកំពុងនាំពិភពលោកឲ្យឈានដល់យុគថ្មីមួយ។

ច្បាស់ណាស់ ឥទ្ធិពលមកលើមនុស្សជាតិពិតជាធំធេងណាស់ដូចគ្នាជាមួយនឹងការអប់រំ និងអាជីពការងារដែរ ខណៈបច្ចេកវិទ្យាកំពុងតែទទួលរ៉ាប់រងការងារធំៗជាច្រើន។ ឧស្សាហកម្មកំពុងផ្លាស់ប្តូរ ដំណើរការរបស់ពួកគេកំពុងឆ្ពោះទៅរកខ្សែចង្វាក់តម្លៃ។ ទោះយ៉ាងណា អ្វីដែលនៅតែជាផ្នែករបស់មនុស្សគឺសមត្ថភាពនៃការច្នៃប្រឌិតរបស់យើង។ ហើយចំណុចនេះយើងត្រូវតែជំរុញ និងលើកកម្ពស់ការអប់រំដល់មនុស្សជំនាន់ក្រោយ។

**Q តើសាកលវិទ្យាល័យ លីមកុកវីង ខុសពីស្ថាប័នឧត្តមសិក្សាដទៃទៀតនៅក្នុងប្រទេសកម្ពុជាដូចម្តេច? ហើយថាតើការអប់រំទំនើបបែបណានៅតែឈរលើគេក្នុងទីផ្សារដ៏ចង្អៀត?**

អ្វីដែលសំខាន់ និងត្រូវចងចាំគឺថាសាកលវិទ្យាល័យយើងមានលក្ខណៈអន្តរជាតិ ដូច្នេះនិស្សិតរបស់យើងគ្រប់រូបអាចចូលទៅក្នុងបណ្តាញសកលយ៉ាងឆាប់រហ័ស។ បណ្តាញនេះមានសហគមន៍និស្សិតសិក្សាតាមអនឡាញ និងអតីតនិស្សិតមកពី១៦០ប្រទេស ហើយយើងបានបង្កើតសាកលវិទ្យាល័យនៅ១៣ប្រទេសក្នុងនោះ១នៅទីក្រុងឡុងដ៍។

បណ្តាញសកលនេះមានតម្លៃយ៉ាងធំធេងសម្រាប់យុវជនក្នុងការស្វែងយល់អំពីវប្បធម៌ដទៃ ហើយទទួលបានព័ត៌មានទីផ្សារតាមរបៀបងាយស្រួល។ សាកលវិទ្យាល័យមានកម្មវិធី Global Campus Programme ដែលលើកទឹកចិត្តនិស្សិតគួរចំណាយពេល១ឆមាស ឬ២សប្តាហ៍នៅក្រៅប្រទេសនៅតាមសាខារបស់យើង។

ការធ្វើបែបនេះពិតជាជួយពង្រីកគំនិតតាមរយៈបទពិសោធជាក់ស្តែងដែលត្រូវបានផ្សារភ្ជាប់ទៅនឹងកម្មវិធីដែលពួកគេធ្វើការស្រាវជ្រាវ និងមានទំនាក់ទំនងជាមួយយីហោល្បីៗដែលយើងបានបង្កើតជាដៃគូយុទ្ធសាស្ត្រ។

កិច្ចសហការរបស់យើងជាមួយឧស្សាហកម្ម ផ្តល់ឱ្យនិស្សិតនូវការចូលរួមដោយផ្ទាល់ជាមួយក្រុមហ៊ុននានា ដែលអាចជួលពួកគេ ហើយក្នុងពេលតែមួយដែលពួកគេទទួលបានការយល់ដឹងដ៏មានតម្លៃចំពោះអ្វីដែលឧស្សាហកម្មរំពឹងពីពួកគេ។

**Q តើគោលនយោបាយអប់រំរបស់កម្ពុជាបានត្រៀមរួចរាល់ដើម្បីឆ្លើយតបទៅនឹងបរិយាកាសសិក្សា និងបច្ចេកវិទ្យានៅសតវត្សរ៍ទី២១ហើយឬនៅ? តើអ្វីខ្លះដែលត្រូវធ្វើដើម្បីពន្លឿនការរៀនសូត្រនៅក្នុងផ្នែកទាំងនេះ?**

ប្រទេសកម្ពុជាបានធ្វើឲ្យមានការរីកចម្រើនគួរឱ្យកោតសរសើរនៅក្នុងការប្តេជ្ញាចិត្តលើកកម្ពស់សមត្ថភាពរបស់ប្រជាជនកម្ពុជា ក្នុងនាមជាអ្នកជំនាញដើម្បីគ្រប់គ្រងកំណើនសេដ្ឋកិច្ចដែលខ្លួនទទួលបានក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ គោលនយោបាយស្តីពីការអប់រំគឺស្ថិតនៅលើគន្លងដ៏ត្រឹមត្រូវ ហើយភាពជោគជ័យនៃផែនការរបស់ខ្លួនស្ថិតនៅក្នុងវិធីដែលគោលនយោបាយទាំងនេះត្រូវបានអនុវត្តនៅតាមមូលដ្ឋាន។ កម្លាំងគុណភាពនៃការបង្រៀនគឺពាក់ព័ន្ធគ្នា និងការសម្រេចចិត្តក្នុងការធានាថា យុវជនរបស់ប្រទេសនេះទទួលបានការបណ្តុះបណ្តាលនិងអប់រំត្រឹមត្រូវ។

ដើម្បីពន្លឿនការសិក្សា យកល្អគួរសម្លឹងឲ្យលើសពីការសិក្សាបែបប្រពៃណី។ វាតម្រូវឱ្យមានភាពក្លាហាន និងស្វាហាប់ក្នុងការធ្វើដូច្នេះ ពីព្រោះវាជាឧបសគ្គដ៏ធំដើម្បីយកឈ្នះ ខណៈឪពុកម្តាយភាគច្រើនធ្វើតាមរបៀបដែលពួកគេធ្លាប់ធ្វើ។ ប៉ុន្តែអនាគតនឹងទាមទារឱ្យយើងផ្លាស់ប្តូរអ្វីៗទាំងអស់ ដូច្នេះរដ្ឋាភិបាល ជាដំបូងប្រហែលជាត្រូវទៅឲ្យដល់ឪពុកម្តាយ ហើយពន្យល់ពួកគាត់ឱ្យទទួលយកនូវការផ្លាស់ប្តូរដែលនឹងកើតឡើង។

មានអ្វីជាច្រើនដែលយើងអាចរៀនបានពីប្រទេសដទៃដូចជាប្រទេសហ្វាំងឡង់ ដែលបានបោះជំហានយ៉ាងធំនៅក្នុងការផ្លាស់ប្តូរការអប់រំ។ រៀនសូត្រពីពួកគេ បន្ទាប់មកយើងអាចប្តូរប្លង់គោលដែលត្រូវនឹងវប្បធម៌និងតម្រូវការសេដ្ឋកិច្ចរបស់ជាតិយើងផ្ទាល់។

តទៅទំព័រអក្សរ G




សាកលវិទ្យាល័យ លីមកុកវីង មានសាលានៅ១៣ប្រទេស។




សាកលវិទ្យាល័យ លីមកុកវីង មានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ។

# ត្រៀមខ្លួនសម្រាប់ឆ្នាំសិក្សាថ្មី និងវិវឌ្ឍជាមួយសាលា SCIA

សាលាអន្តរជាតិសិង្ហបុរី (SCIA) ព្យាយាមនាំមកនូវការអប់រំស្តង់ដាសិង្ហបុរីដែលមានគុណភាពខ្ពស់មកកាន់រាជធានីភ្នំពេញ។ ដើម្បីសម្រេចបាននូវគោលដៅនេះយើងត្រូវបន្តអនុវត្តយុទ្ធសាស្ត្រល្អៗដែលរួមចំណែកដល់ភាពជោគជ័យនៃប្រព័ន្ធអប់រំរបស់សិង្ហបុរី។

កត្តាជោគជ័យសំខាន់មួយគឺផ្តោតលើទស្សនៈវែងឆ្ងាយចំពោះការអប់រំរបស់កុមារគ្រប់រូប។

ចំណុចនេះគឺពាក់ព័ន្ធនឹងការកសាងប្រព័ន្ធអេកូ ដែលឪពុកម្តាយសិស្សានុសិស្ស និងសាលារៀនត្រូវធ្វើការរួមគ្នាឲ្យបានជិតស្និទ្ធ។ គ្រូបង្រៀនរបស់សាលា SCIA សហការជាមួយឪពុកម្តាយដើម្បីរៀបចំផែនការសម្រាប់ដំណើរសិក្សារបស់សិស្ស ដោយរៀបចំពួកគេឱ្យបានល្អសម្រាប់ដំណាក់កាលសិក្សានីមួយៗ និងធានាថាពួកគេត្រៀមខ្លួនបានល្អបំផុត ដើម្បីវិវឌ្ឍន៍ទៅរកការជ្រើសរើសសាកលវិទ្យាល័យ និងអាជីពដែលពួកគេពេញចិត្ត។

ក្នុងអំឡុងពេលវិស្សមកាល វាចាំបាច់ណាស់សម្រាប់សិស្សានុសិស្សត្រៀមខ្លួនសម្រាប់ឆ្នាំសិក្សាថ្មី។ ការវិលត្រឡប់ទៅកាន់សាលារៀនវិញអាចពិបាកបន្តិចសម្រាប់សិស្សដែលមានទម្លាប់នៅផ្ទះ ជាពិសេសការបិទសាលាដោយសារជំងឺកូវីដ១៩។ នេះគឺជាការណែនាំមួយចំនួនដែលសាលា SCIA ចង់ចែករំលែក ដើម្បីយើងរួមគ្នាធ្វើការរៀបចំផែនការនិងត្រៀមខ្លួនទុកជាមុនឱ្យបានល្អដើម្បីជួយកូនៗរបស់លោកអ្នកឆ្ពោះទៅរកមាគ៌ានៃជម្រើសរបស់ពួកគេ។



សាលា SCIA ព្យាយាមនាំការអប់រំស្តង់ដាសឹង្ហបុរីសម្រាប់សិស្សានុសិស្សកម្ពុជា។

**រៀបចំផែនការទុកជាមុន៖** យកគោលដៅជាចំណុចចាប់ផ្តើមនៃការគិត។ ណែនាំកូនរបស់លោកអ្នកឱ្យកំណត់គោលដៅ SMART (ដែលជាក់លាក់អាចវាស់វែងបាន អាចសម្រេចបាន មានការទាក់ទងនិងទាន់ពេលវេលា) និងរៀបចំដំណើររបស់ពួកគេប្រចាំឆ្នាំ។ គោលដៅនេះគួរតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ៖ ក្រៅពីចំណាត់ថ្នាក់សិក្សា គួរតែមានចំណុចសំខាន់ៗសម្រាប់ការរីកចម្រើនផ្ទាល់ខ្លួន និងការអភិវឌ្ឍអត្តចរិត។ គោលដៅ SMART ផ្តល់ឱ្យកូនអ្នកនូវអត្ថន័យ ការលើកទឹកចិត្ត និងហេតុផលដើម្បីចេះតស៊ូនៅពេលមានរឿងលំបាកកើតឡើង។

**រៀបចំឱ្យបានល្អ៖** ជាមួយនឹងគោលដៅដែលបានកំណត់ វាដល់ពេលដែលត្រូវធ្វើសកម្មភាព។ នៅមុនចាប់ផ្តើមឆមាសថ្មី ត្រូវប្រាកដថា កូនរបស់អ្នកមានសម្ភារសិក្សាគ្រប់គ្រាន់។ រៀបចំកន្លែងសិក្សានៅផ្ទះ មានទម្លាប់សិក្សា ហើយចាប់ផ្តើមអនុវត្តយ៉ាងហោចណាស់២សប្តាហ៍មុនពេលចាប់ផ្តើមឆមាសថ្មី។ សម្រាប់សិស្សដែលផ្លាស់ទៅសាលាថ្មី ប្រសិនបើអាចត្រូវស្គាល់ពីបរិស្ថានជុំវិញ និងគ្រូថ្មី។ ការរៀនសូត្រពេញមួយជីវិតគឺជាការចាំបាច់។

**វឌ្ឍនភាពឆ្ពោះទៅរកផ្លូវនៃជម្រើស៖** ពេលវិស្សមកាល គឺជាពេលវេលាដ៏ល្អសម្រាប់ឆ្លុះបញ្ចាំង សម្រាប់ភាពស្រស់ស្រាយ និងស្វែងរកចំណង់ចំណូលចិត្តរបស់មនុស្សម្នាក់ៗ។ ចំណុចនេះទាក់ទងជាពិសេសជាមួយសិស្សវិទ្យាល័យដែលកំពុងស្ថិតក្នុងដំណាក់កាលគិតអំពីអនាគតសាកលវិទ្យាល័យនិងមាគ៌ាអាជីពរបស់ពួកគេ។ បុគ្គលិកសិក្សារបស់សាលា SCIA បានធ្វើការយ៉ាងជិតស្និទ្ធជាមួយសិស្សានុសិស្សនៅក្នុងដំណើរការស្វែងយល់អំពីខ្លួនឯង និងពន្យល់ណែនាំពួកគេអំពីជម្រើសនៃការសិក្សា។ យើងប្រើវិធីសាស្ត្រ «3D4L» ដើម្បីជួយសិស្សឱ្យចេះស្វែងរក បង្កើត និងសម្រេចចិត្ត(3D) តាមរយៈការរៀនសូត្រ (4L) បន្ថែមទៀតអំពី (1) ចំណាប់អារម្មណ៍របស់ពួកគេ (2 ) សេចក្តីប្រាថ្នា (3) ជំនាញ និងទេពកោសល្យ និង (៤) ឱកាស។

រៀបចំផែនការ ត្រៀមខ្លួន និងវិវឌ្ឍជាមួយសាលា SCIA ។ នៅក្នុងឆ្នាំសិក្សាខាងមុខសាលា SCIA នឹងបើកវគ្គបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយបន្ថែម សិក្ខាសាលាសម្រាប់ឪពុកម្តាយ និង«3D4L» សិក្ខាសាលាស្តីពីការអប់រំនិងអាជីព ដើម្បីបង្កើតប្រព័ន្ធអេកូនៃសាលាអន្តរជាតិ K12 របស់យើង។ យើងជឿជាក់ថា តាមរយៈការរៀបចំផែនការ ត្រៀមខ្លួន និងវឌ្ឍនភាព សិស្សនឹងត្រូវបានបំពាក់នូវជំនាញនិងលក្ខណសម្បត្តិចាំបាច់ដើម្បីទទួលបានជោគជ័យសម្រាប់អនាគតរបស់ពួកគេ។ ចាប់ដៃគូជាមួយយើងដើម្បីផ្តល់នូវការអប់រំដ៏ល្អបំផុតសម្រាប់កូនរបស់លោកអ្នក៕ ■



# គួរពិចារណាឡើងវិញចំពោះវិធីសាស្ត្រនៃការបង្រៀន

បន្ទាប់ពីបានផ្អាកអស់រយៈពេលជិត៤ខែកន្លងមកនេះ ស្ថាប័នអប់រំនានានៅទូទាំងប្រទេសដែលបានបិទទ្វារដោយសារការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ពេលនេះកំពុងតែមមាញឹកក្នុងការរៀបចំបើកសាលាឡើងវិញ និងរង់ចាំការអនុញ្ញាតចុងក្រោយពីរាជរដ្ឋាភិបាល។

ការបិទសាលាភ្លាមៗ បណ្តាលឱ្យមានបញ្ហាជាច្រើនសម្រាប់អ្នកបង្កើតគោលនយោបាយ សាលារៀន គ្រឹះស្ថានឧត្តមសិក្សា គ្រូបង្រៀន សិស្សានុសិស្ស និងឪពុកម្តាយ ដែលមិនទាន់ត្រូវបានដោះស្រាយឱ្យបានពេញលេញនៅឡើយ។ វិបត្តិជំងឺកូវីដបានប៉ះពាល់យ៉ាងខ្លាំងដល់វិស័យអប់រំ និងសុខភាពទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសដទៃនៅលើពិភពលោក។

លោកបណ្ឌិតយៀង សុធី ទីប្រឹក្សានៃមជ្ឈមណ្ឌលសេដ្ឋកិច្ចឌីជីថលប្រកបដោយបរិយាប័ន្ន, វិទ្យាស្ថានចក្ខុវិស័យអាស៊ី ដែលមានស្នាក់ការនៅទីក្រុងភ្នំពេញបានមានប្រសាសន៍ថា៖«ការបិទសាលារៀនភ្លាមៗបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការអប់រំ ដែលបានផ្លាស់ប្តូរពីការរៀននៅសាលាទៅជាការរៀនតាមអនឡាញ។ អ្នកសិក្សាដែលមានភាពឯករាជ្យច្រើន និងអ្នកដែលនិយមសិក្សាតាមបែបឌីជីថល និងអ្នកចេះភាសាអង់គ្លេស មិនសូវទទួលរងផលប៉ះពាល់ច្រើនពីការបិទសាលានេះទេ»។

«ការនៅដាច់ឆ្ងាយពីសាលារៀន និងកង្វះទំនាក់ទំនងសង្គមជាមួយមិត្តភក្តិ និងរវាងគ្រូ និងសិស្ស បានបង្កើតឲ្យមានភាពតានតឹងនិងបញ្ហាផ្លូវចិត្តជាច្រើនទៀតក្នុងចំណោមសិស្សានុសិស្ស។ ហើយទាំងនេះបានជះឥទ្ធិពលដោយផ្ទាល់និងដោយប្រយោលដល់សមត្ថភាពសិក្សានិងសមិទ្ធផលនៃការសិក្សា»។

ការបិទសាលាបណ្តោះអាសន្នដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ បាននាំមកនូវការផ្លាស់ប្តូរដែលមិននឹកស្មានដល់ ចំពោះវិធីសាស្ត្របង្រៀន និងការវាយតម្លៃការសិក្សានៅតាមសាលារៀន និងសាកលវិទ្យាល័យ។

វិធីសាស្ត្របង្រៀនតាមទម្លាប់ ដែលប្រើដីស និងក្តារខៀនត្រូវបានផ្អាកខណៈការសិក្សាតាមអនឡាញបានក្លាយជាពាក្យដែលគេឮនៅក្នុងវិជ្ជាជីវៈនៃការបង្រៀន ហើយច្បាស់ណាស់ថា ស្ថាប័នជាច្រើនអាចត្រូវបង្ខំចិត្តអនុវត្តទិសដៅនេះសម្រាប់រយៈពេលមិនកំណត់។

សាលារៀន និងស្ថាប័នឯកជនកំពុងរៀបចំថ្នាក់រៀន ហេដ្ឋារចនាសម្ព័ន្ធ និងវិធីសាស្ត្របង្រៀនរបស់ពួកគេឡើងវិញដើម្បីឆ្លើយតបនឹងវិធានការសុវត្ថិភាពថ្មី និងវិធានការអនាម័យដើម្បីបង្កើតបរិយាកាសមានផាសុកភាពសម្រាប់សិស្ស។

លោកបណ្ឌិតសុធី ថ្លែងថា៖«ការសិក្សាតាមអនឡាញ និងពីចម្ងាយនឹងបន្តនៅដដែល ហើយតួនាទីរបស់គ្រូនឹងត្រូវបានផ្លាស់ប្តូរពីការផ្ទេរចំណេះដឹង និងជំនាញជាទម្លាប់ទៅជាអ្នកសម្របសម្រួល និងជាគ្រូបង្វឹកវិញ»។

«ការសិក្សាតាមប្រព័ន្ធអនឡាញមិនមែនគ្រាន់តែជាការបញ្ជាំងស្លាយប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាការផ្លាស់ប្តូរការផ្តោតអារម្មណ៍ ពីការបង្រៀនទៅជាការរៀន ផ្តោតពីគ្រូទៅសិស្ស ជាវិធីសាស្ត្រមួយដែលមានលក្ខណៈស្តង់ដាអាចទទួលបានគ្រប់គ្នា ប្រកបដោយភាពបត់បែន និងមានគុណភាព»។

«ការរួមបញ្ចូលគ្នានៃការសិក្សាក្នុងថ្នាក់និងតាមប្រព័ន្ធអេឡិចត្រូនិក និងការសិក្សាពីចម្ងាយ នឹងធ្វើឲ្យប្រសើរឡើងនូវគុណភាពអប់រំ និងពាក់ព័ន្ធដល់អ្នកសិក្សាវ័យក្មេងជាច្រើន ដែលមានចំណេះដឹងខាងបច្ចេកវិទ្យា និងមានចំណាប់អារម្មណ៍ខ្ពស់»។

លោកបណ្ឌិតសុធីបានបន្ថែមថា៖«ការសិក្សានៅក្នុងថ្នាក់ នៅតាមសាកលវិទ្យាល័យគួរតែត្រូវបានប្រើសម្រាប់ការពិភាក្សា ការជជែកវែកញែក ណែនាំ ឬជាបន្ទប់ពិសោធន៍ជាក់ស្តែងច្រើនជាងការបង្រៀន»។

លោកបណ្ឌិតសុធីក៏បានតើនរំឭកផងដែរថាគ្រឹះស្ថានអប់រំឯកជនដែលមិនមានគុណភាពនិងមិនវិនិយោគលើការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងហេដ្ឋារចនាសម្ព័ន្ធដែលអំណោយផលដល់ការសិក្សារបស់សិស្សនឹងកាន់តែទទួលឥទ្ធិពលអវិជ្ជមាន៕ ■



លោកបណ្ឌិត យៀង សុធី ។






# លោកវេជ្ជបណ្ឌិត គួច ម៉េងលី លើកទឹកចិត្តឲ្យចូលរួមកម្មវិធី summer school ដើម្បីធានាការសុវត្ថិភាពមុនបើកសាលា

ជាមួយនឹងការប្រកាសឲ្យបើកសាលារៀនឡើងវិញជាបណ្តើរៗនោះ លោកឧកញ៉ាវេជ្ជបណ្ឌិត គួច ម៉េងលី ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយកប្រតិបត្តិនៃក្រុមហ៊ុន ម៉េងលី ជេ.គួច អេឌ្យូខេសិន (MJQE) បានថ្លែងអំណរគុណដល់រដ្ឋាភិបាល និងក្រសួងអប់រំចំពោះការដោះស្រាយវិបត្តិជំងឺកូវីដ១៩ និងអនុញ្ញាតកម្មវិធី summer school បើកដំណើរការនៅក្នុងបរិវេណសាលា។



ក្រុមហ៊ុន MJQE គឺជាក្រុមហ៊ុនមេនៃមជ្ឈមណ្ឌលភាសា អេ អាយ អាយ (Aii) និងសាលារៀនអន្តរទ្វីបអាមេរិកាំង(AIS) ដែលមានសិស្សចូលរៀន ១៤ ៥០០ នាក់។

MJQE គឺជាក្រុមហ៊ុនមេនៃមជ្ឈមណ្ឌលភាសាអេ អាយ អាយ (Aii) និងសាលារៀនអន្តរទ្វីបអាមេរិកាំង (AIS)។ កម្មវិធី summer school របស់សាលា AIS នឹងចាប់ផ្តើមនៅខែសីហាហើយលោកវេជ្ជបណ្ឌិតគួច ម៉េងលី កំពុងស្នើដល់រដ្ឋាភិបាលឲ្យអនុញ្ញាតឲ្យពួកគេធ្វើកម្មវិធីនេះនៅក្នុងថ្នាក់រៀនដើម្បីធានាថា កម្រិតសុវត្ថិភាពគឺជាអាទិភាពខ្ពស់បំផុតមុនពេលសាលារៀនបើកដំណើរការឡើងវិញ។

ទន្ទឹមនឹងនេះដែរ លោកមានប្រសាសន៍ថា ការបិទសាលារៀនដើម្បីប្រយុទ្ធប្រឆាំងការរីករាលដាលជំងឺកូវីដបានធ្វើឲ្យប៉ះពាល់វិស័យអប់រំឯកជនយ៉ាងខ្លាំង ដោយស្ថាប័នអប់រំតូចៗជាច្រើននៅទូទាំងប្រទេសបានត្រូវបិទទ្វារ ប៉ុន្តែសេចក្តីប្រកាសនេះបានធ្វើឱ្យមានសុទិដ្ឋិនិយមជាមួយនឹងលក្ខខណ្ឌសម្រាប់កម្មវិធី summer schoolដែលនឹងចាប់ផ្តើមនាពេលខាងមុខដ៏ខ្លី។



លោកឧកញ៉ាវេជ្ជបណ្ឌិត គួច ម៉េងលី ស្ថាបនិកក្រុមហ៊ុន MJQE ។

«ខ្ញុំសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលដែលបានធានាសុវត្ថិភាពរបស់ប្រជាជនក្នុងអំឡុងពេលមានវិបត្តិជំងឺរាតត្បាតសកលដែលមិនធ្លាប់មាននេះ ហើយខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួងអប់រំផងដែរចំពោះការយកចិត្តទុកដាក់របស់ពួកគេ និងចំពោះការធានាដល់សាលារៀនឪពុកម្តាយ និងសិស្សានុសិស្សដែលបានបើកភ្លើងខៀវដើម្បីឲ្យចាប់ផ្តើមបើកសាលាឡើងវិញ»។

«ការប្រកាសនេះគឺជាដំណឹងល្អសម្រាប់វិស័យនេះ និងសម្រាប់សាលារៀនដូចពួកយើងដែលនឹងចាប់ផ្តើមឆមាសថ្មីនៅខែតុលាឬខែវិច្ឆិកាខាងមុខ។ សម្រាប់យើង យើងអាចបន្តផ្តល់អាហារូបករណ៍និងចាប់ផ្តើម summer school នៅក្នុងថ្នាក់រៀនដើម្បីរៀបចំសម្រាប់ឆមាសថ្មី។ ប្រសិនបើយើងអាចបើកនៅខែសីហានោះ យើងអាចដំណើរការកម្មវិធី summer school នៅក្នុងថ្នាក់រៀនដោយឥតគិតថ្លៃដើម្បីត្រៀមឆមាសថ្មី»។

លោកវេជ្ជបណ្ឌិតម៉េងលី ថ្លែងថា៖ «ខណៈសិស្សចូលចូលរួម summer school តិច នឹងអនុញ្ញាតឱ្យធ្វើនៅក្នុងបរិវេណសាលាបាននឹងធ្វើជាការហាត់សមសម្រាប់ការបើកសាលាឡើងវិញដើម្បីធានាថា វិធានការសុវត្ថិភាពគឺជាអាទិភាពខ្ពស់បំផុត»។

លោកវេជ្ជបណ្ឌិតបន្ថែមថា វិធានការបែបនេះក៏នឹងជួយ«ជំរុញលើកទឹកចិត្ត» សិស្សមុនពេលពួកគេត្រឡប់មកកាន់ថ្នាក់រៀនវិញ។

«សិស្សានុសិស្សកំពុងនិយាយថាពួកគេនឹកសាលាហើយពួកគេកំពុងទន្ទឹងរង់ចាំមកជួបជុំមិត្តភក្តិ និងគ្រូរបស់ពួកគេ និងត្រឡប់មកកាន់ការអប់រំបានប្រក្រតីឡើងវិញ»។

«summer school របស់យើងនឹងចាប់ផ្តើមពីថ្ងៃទី២៤ ខែសីហាដល់ថ្ងៃទី២ ខែតុលា។ យើងបើកកម្មវិធី summer school ជារៀងរាល់ឆ្នាំដើម្បីត្រៀមសិស្សសម្រាប់ឆ្នាំសិក្សាខាងមុខ។ ប៉ុន្តែឆ្នាំនេះមានការលំបាកដោយសារការបិទសាលាដើម្បីទប់ស្កាត់កូវីដ១៩។ វារឹតតែសំខាន់ទៀតដែលយើងអាចដំណើរការកម្មវិធីនេះបាននៅក្នុងបរិវេណសាលាដើម្បីផ្តល់ឱកាសដល់សិស្សឲ្យទទួលបានផ្នត់គំនិតអប់រំឡើងវិញ និងទទួលបានការបំផុសគំនិតម្តងទៀត ដើម្បីរៀបចំសម្រាប់ឆមាសថ្មីនិងដើម្បីធានាដល់ឪពុកម្តាយ»។

ស្ថាបនិកនៃ Aii និង AIS ដែលមានសិស្សចូលរៀនប្រមាណ១៤ ៥០០ នាក់ គិតចាប់តាំងពីត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៥ មកនោះបានថ្លែងថា៖«ខណៈកម្មវិធី summer school របស់យើងរៀបចំឡើងដោយឥតគិតថ្លៃ ស្ថាប័នអប់រំផ្សេងទៀតអាចប្រើប្រាស់ប្រាក់ចំណូលដើម្បីរក្សាស្ថិរភាពរបស់ពួកគេ បន្ទាប់ពីវាបានប៉ះពាល់ដល់ហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរដែលបណ្តាលមកពីការបិទទ្វារសាលា»។

ខណៈសាលារៀនកំពុងរៀបចំដំណើរការបើកឡើងវិញនោះ ពួកគេត្រូវតែប្រកាន់ខ្ជាប់គោលការណ៍ណែនាំដែលបានកំណត់ដោយអង្គការសុខភាពពិភពលោក និងក្រសួងសុខាភិបាល។

«ក្នុងនាមជាវេជ្ជបណ្ឌិត និងជាអ្នកឯកទេសខាងសុខភាពសាធារណៈខ្ញុំតែងតែធានាថា សាលារៀនរបស់ខ្ញុំមានស្តង់ដាអនាម័យតឹងរ៉ឹងបំផុត។ យើងមានគុណសម្បត្តិជាច្រើនរួចហើយ និងបានរៀបចំយ៉ាងល្អ ខណៈសាលាកំពុងរៀបចំបើកដំណើរការឡើងវិញ»។

«សូម្បីតែមុនពេលផ្ទុះជំងឺកូវីដ១៩ យើងបានអនុវត្តតាមស្តង់ដាអនាម័យតឹងរ៉ឹងបំផុត ហើយបុគ្គលិករបស់យើងក៏ទទួលបានការបណ្តុះបណ្តាលយ៉ាងល្អ។បន្ទប់ទឹករបស់យើងត្រូវបានសម្អាតរៀងរាល់ម៉ោងខណៈអគារទាំងអស់របស់យើងត្រូវបានសម្អាតយ៉ាងស្អាតជារៀងរាល់សប្តាហ៍»។

លោកវេជ្ជបណ្ឌិតមានប្រសាសន៍ថា៖ «យើងក៏ជាសាលាតែមួយគត់ដែលមានមជ្ឈមណ្ឌលសុខភាពពេញលេញសម្រាប់សិស្ស យើងមានគ្រូពេទ្យ និងគិលានុបដ្ឋាយិកាប្រចាំការជាប្រចាំ ហើយយើងពិតជាមានមោទនភាពណាស់ចំពោះរឿងនេះ»។

លោកបន្តថា ដោយមានវិធានការបែបនេះរួចជាស្រេច សាលារបស់លោកបានត្រៀមស្វាគមន៍សិស្សត្រឡប់មកវិញរួចរាល់ដើម្បីផ្តល់ឲ្យពួកគេនូវទំនុកចិត្តខណៈដែលវិស័យអប់រំនៅកម្ពុជាកំពុងផ្លាស់ប្តូរទៅដំណាក់កាលថ្មី។

«បន្ទាប់ពីមានការផ្ទុះឡើងនៃវីរុសនេះ ថ្នាក់រៀនរបស់យើងទាំងអស់ត្រូវបានបើកឲ្យខ្យល់អាកាសបរិសុទ្ធចេញចូលគ្រប់គ្រាន់ ហើយរក្សាសីតុណ្ហភាពអប្បបរមាគឺ២៤អង្សាសេ។ ខណៈការពាក់ម៉ាស់គឺចាំបាច់វិធានការគម្លាតសង្គម និងការលាងដៃដើម្បីរក្សាអនាម័យ នឹងត្រូវអនុវត្តយ៉ាងតឹងរ៉ឹងបំផុត»។

លោកវេជ្ជបណ្ឌិត ម៉េងលី បន្តថា៖ «ខ្ញុំគឺជាមនុស្សដំបូងគេដែលចេញវីដេអូដើម្បីផ្តល់ដំបូន្មានដល់ប្រជាជនឲ្យយល់ដឹងអំពីសារៈសំខាន់នៃការធ្វើអនាម័យដើម្បីប្រយុទ្ធប្រឆាំងនឹងវីរុសនេះ ចាប់តាំងពីមេរោគនេះផ្ទុះឡើងដំបូងម្ល៉េះហើយការប្តេជ្ញាចិត្តរបស់ខ្ញុំចំពោះសុវត្ថិភាពសាធារណៈគឺនៅដដែលមិនការមានផ្លាស់ប្តូរឡើយ»៕ ■



ប្រកាន់ខ្ជាប់វិធានការគម្លាតនៅពេលសាលាបើកឡើងវិញ។



សាលារបស់ក្រុមហ៊ុន MJQE ទាំងអស់ត្រូវបានសម្អាតជាប្រចាំ។



សាលា AIS មានស្តង់ដាអនាម័យខ្ពស់បំផុត។

# តើគួរអនុវត្តប្រព័ន្ធអប់រំពីចម្ងាយយ៉ាងដូចម្តេច ដើម្បីអាចធានាបាននូវគុណភាព?

ក្នុងកាលៈទេសៈបច្ចុប្បន្នជំងឺកូវីដ១៩ បានរីករាលដាលពាសពេញពិភពលោក ដែលធ្វើឲ្យមានការប៉ះពាល់យ៉ាងខ្លាំងទៅលើគ្រប់វិស័យ។ទម្លាប់ជាច្រើនក្នុងជីវភាពរស់នៅ ក្នុងធុរកិច្ច និងការគ្រប់គ្រងផ្សេងៗត្រូវបានផ្លាស់ប្តូរយ៉ាងរហ័សដើម្បីទប់ស្កាត់ការពារនឹងការឆ្លងរាលដាលនៃវីរុសថ្មីមួយនេះ និងដើម្បីធានាឲ្យបាននូវដំណើរប្រតិបត្តិការការងារផ្សេងៗឲ្យមានតុល្យភាព ជាពិសេសវិស័យសុខាភិបាល សេដ្ឋកិច្ច និងការអប់រំ។ នៅពេលដែលធនធានមនុស្ស គឺជាកត្តាចម្បងបំផុត សម្រាប់គ្រប់វិស័យ និងគ្រប់ស្ថានការណ៍។

ស្របពេលនេះ វិស័យអប់រំរបស់ប្រទេសកម្ពុជាក៏ត្រូវបានរងឥទ្ធិពល ដែលតម្រូវឲ្យសាលារៀន និងវិទ្យាស្ថានអប់រំ ទាំងរដ្ឋ និងឯកជនធ្វើការផ្លាស់ប្តូរពីការអប់រំបែបប្រពៃណី មកជាការសិក្សាពីចម្ងាយដោយពឹងផ្អែកលើបច្ចេកវិទ្យាជាចម្បង។ ជាមួយគ្នានេះ សាកលវិទ្យាល័យន័រតុន បានធ្វើការរៀបចំនូវយន្តការសម្រាប់អនុវត្តប្រព័ន្ធអប់រំពីចម្ងាយ។ យន្តការនេះត្រូវបានផ្សព្វផ្សាយ និងបកស្រាយដោយលោកបណ្ឌិត អ៊ុង វ៉ាន់ធឿន សាកលវិទ្យាធិការរង និងជាព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដែលរួមមានយន្តការធំៗចំនួន២ គឺ៖

១-យន្តការផ្ទាល់៖ ជាថ្នាក់រៀនតាមបែបបច្ចេកវិទ្យា ដោយធ្វើការផ្សាយផ្ទាល់រវាងគ្រូ និងសិស្ស។ កម្មវិធីដែលគាំទ្រយន្តការនេះគឺ Zoom, Google meet, YouTube និង Facebook ជាដើម។

២- យន្តការមិនផ្ទាល់៖ ជាថ្នាក់រៀនបន្ទាប់បន្សំ ដែលលោកគ្រូ អ្នកគ្រូដាក់ការងារ កិច្ចការស្រាវជ្រាវ ផ្ញើឯកសារ សេចក្តីណែនាំ និងលំហាត់ផ្សេងៗឲ្យសិស្សធ្វើ ក៏ដូចជាបញ្ជូនមកវិញដើម្បីឲ្យគ្រូពិនិត្យ។ កម្មវិធីដែលគាំទ្រយន្តការនេះគឺ Google classroom, Schoology, Wiki school និង Class Dojo។

បច្ចុប្បន្ន យន្តការទាំង២នេះកំពុងក្លាយជាកម្មវិធីសិក្សាផ្លូវការមួយ និងជាតម្រូវការចាំបាច់សម្រាប់និស្សិតដែលសិក្សានៅសាកលវិទ្យាល័យន័រតុន។ គន្លឹះដែលសំខាន់មួយទៀតនោះគឺការអាន។ ការអាននឹងជួយដល់ការរៀនសូត្រ និងការស្រាវជ្រាវដល់សិស្ស និស្សិត និងសាស្ត្រាចារ្យបានយ៉ាងមានប្រសិទ្ធភាព។

ជាមួយគ្នានេះដែរ គណៈកម្មការបច្ចេកទេសក៏បានធ្វើការកែទម្រង់លើប្រព័ន្ធដាក់ពិន្ទុខ្លះៗ គឺយើងធ្វើការ



ប្រព័ន្ធត្រួតពិនិត្យពិសេស នឹងត្រូវដាក់ដើម្បីតាមដានវត្តមាន។

រឹតបន្តឹងបន្ថែមទៅលើវត្តមាន និងការចូលរួមក្នុងកិច្ចការផ្សេងៗរបស់មុខវិជ្ជានីមួយៗ។ សាស្ត្រាចារ្យទាំងអស់បានធ្វើការអភិវឌ្ឍគម្រោងបង្រៀនថ្មីដើម្បីឲ្យស្របសភាពការណ៍។ ក្នុងកិច្ចការបង្រៀនថ្មីនេះ តម្រូវឲ្យសាស្ត្រាចារ្យទាំងអស់ ភ្ជាប់ជាមួយនឹងកិច្ចការ ឬលំហាត់ក្រោយបញ្ចប់ម៉ោងសិក្សានីមួយៗ។ នេះជាវិធីដើម្បីធ្វើការសាកល្បងសមត្ថភាពភ្លាមៗ និងដើម្បីជាការតាមដាននូវវិន័យសិក្សារបស់និស្សិត។

បុគ្គលិកអប់រំ ក្នុងសាកលវិទ្យាល័យន័រតុនទាំងអស់ គឺតាមដានយ៉ាងយកចិត្តដាក់ចំពោះសកម្មភាពបង្រៀន និងតែងតែនៅរង់ចាំផ្តល់ជំនួយដល់សាស្ត្រាចារ្យ និងនិស្សិតដែលជួបបញ្ហាបច្ចេកទេសផ្សេងៗ។

ការអប់រំបែបថ្មីនេះពិតជាមានផលលំបាកមួយចំនួន ហើយតម្រូវឲ្យធ្វើការរៀនសូត្រ និងស្រាវជ្រាវលើរបស់ថ្មីៗជាច្រើន ប៉ុន្តែបើយើងអាចឆ្លងកាត់ និងទទួលយកប្រព័ន្ធអប់រំពីចម្ងាយនេះបានក្នុងដំណាក់កាលលំបាកនេះ គឺជាទុនដ៏ប្រសើរមួយក្នុងបរិបទអប់រំនាពេលអនាគត។

ខណៈបច្ចុប្បន្ន ភាពរីកចម្រើននៃឧស្សាហកម្ម ៤.0 កំពុងរីកលូតលាស់ និងត្រូវបានជំរុញឲ្យអនុវត្តលើគ្រប់វិស័យ។

នេះគឺជាឱកាសសម្រាប់បុគ្គលិកអប់រំ សាស្ត្រាចារ្យ និងសិស្សនិស្សិត ដើម្បីដុសខាត់សមត្ថភាពរបស់ពួកគេឲ្យបានកាន់តែល្អ។ ដូច្នេះ មិនថា ស្ថិតនៅក្នុងកាលៈទេសៈបែបណាទេ ត្រូវធានាឲ្យបាននូវនិរន្តភាព និងស្ថិរភាពនៃ វិស័យអប់រំ និងបណ្តុះបណ្តាលដែលប្រកបដោយគុណភាព៕ ■



# និស្សិតបញ្ចប់ការសិក្សានៅ CamEd ធ្វើឱ្យមានឥទ្ធិពលនៅក្នុងពិភពសាជីវកម្ម

អស់រយៈពេល២ទសវត្សរ៍កន្លងមកនេះ វិទ្យាស្ថាន CamEd Business School បានបណ្តុះបណ្តាលនិស្សិតវ័យក្មេងកម្ពុជាជាច្រើននាក់បានជោគជ័យបំផុតសម្រាប់វិស័យហិរញ្ញវត្ថុ។

ចក្ខុវិស័យរបស់ប្រធាន និងស្ថាបនិកវិទ្យាស្ថាន CamEd លោក Casey Barnett គឺផ្លាស់ប្តូរ CamEd ឲ្យក្លាយទៅជាសាលាធុរកិច្ចដ៏លេចធ្លោមួយ ដើម្បី«អភិវឌ្ឍសហគមន៍អ្នកជំនាញគណនេយ្យ និងហិរញ្ញវត្ថុឲ្យស្របទៅនឹងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ» បានក្លាយជាការពិតហើយ។

បច្ចុប្បន្ន សាលាធុរកិច្ចឯកជនមួយនេះបានកសាងកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងការបង្កើតគណនេយ្យករ និងហិរញ្ញវត្ថុជំនាញ ដោយពួកគេទទួលបានការងារល្អ ប្រាក់ខែខ្ពស់ នៅក្នុងឧស្សាហកម្មធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា។

លោកស្រី សំ សុគន្ធារី នាយិការងរបស់វិទ្យាស្ថានCamEd មានប្រសាសន៍ថា៖ «គុណភាពនិស្សិតរបស់យើងត្រូវបានទទួលស្គាល់ដោយក្រុមហ៊ុនសវនកម្មអន្តរជាតិល្បីៗដូចជា PWC, KPMG, Deloitte និង Ernst និង Young ជាដើម ហើយបុគ្គលិកសិក្សារបស់យើងមានសាស្ត្រាចារ្យអន្តរជាតិ ដែលមានសមត្ថភាព ហើយយើងប្រើប្រាស់បច្ចេកវិទ្យា និងប្រព័ន្ធអប់រំកម្រិតខ្ពស់»។


លោកដារិទ្ធ៖ ACCA ផ្តល់ឲ្យខ្ញុំនូវទំនុកចិត្តដែលខ្ញុំត្រូវការដើម្បីដោះស្រាយរាល់បញ្ហាប្រឈមក្នុងអាជីព។

វិទ្យាស្ថាន CamEd ផ្តល់ជូនវគ្គសិក្សាមួយដែលមានការទទួលស្គាល់ខ្ពស់បំផុតនៅលើពិភពលោកគឺវគ្គគណនេយ្យករជំនាញ( ACCA )ដែលមានតម្រូវការខ្ពស់បំផុតពីនិយោជក និងថ្នាក់សញ្ញាបត្រជំនាញអ្នកបច្ចេកទេសគណនេយ្យ ( CAT )ជាវគ្គសិក្សាដែលផ្តល់នូវជំនាញគណនេយ្យខ្ពស់បំផុត។

លោកស្រី សុគន្ធារី បានថ្លែងថា៖ «និស្សិតគួរតែចូលរៀនវគ្គសិក្សាទាំងនេះ ពីព្រោះគណនេយ្យករជំនាញសវនករពន្ធដារ និងអ្នកប្រឹក្សាពន្ធដារដែលមានចំណេះដឹង បទពិសោធ និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ គឺមានតម្រូវការខ្ពស់ពីវិស័យឯកជន និងសាធារណៈ»។

CamEd ក៏ជាវិទ្យាស្ថានធុរកិច្ចដ៏ល្អបំផុតសម្រាប់សហគ្រិនជោគជ័យផងដែរ។ លោក យុន ដារិទ្ធ អតីតនិស្សិតបញ្ចប់ការសិក្សាវគ្គ ACCA នៅវិទ្យាស្ថាន CamEd ដែលបច្ចុប្បន្នលោកជា managing partner នៃក្រុមហ៊ុន K Professional Accountants បានចែករំលែកពីប្រវត្តិនៃការសិក្សារបស់លោកដ៏គួរឲ្យចាប់អារម្មណ៍។

លោកដារិទ្ធ ថ្លែងថា៖ «ការសម្រេចចិត្តចាប់ផ្តើមដំណើររបស់ខ្ញុំជាមួយវគ្គសិក្សា ACCA កាលពីច្រើនឆ្នាំមុនគឺជាជម្រើសដ៏ឈ្លាសវៃបំផុតដែលខ្ញុំមិនធ្លាប់មាន ហើយខ្ញុំមិនអាចបរិយាយអស់នូវអ្វីដែល ACCA បានកែប្រែជីវិតផ្ទាល់ខ្លួន និងអាជីពរបស់ខ្ញុំនោះទេ»។

ជាមួយនឹងការទទួលបានចំណាត់ថ្នាក់ដ៏ល្អពីការសិក្សាវគ្គ ACCA លោកដារិទ្ធ ត្រូវបានតែងតាំងឲ្យក្លាយជាអ្នកត្រួតពិនិត្យ និងគាំទ្រដល់ប្រទេសជាច្រើននៅតំបន់អាស៊ី និងអាហ្វ្រិកស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុប្រទេស សវនកម្ម ការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងផ្ទៃក្នុង និងអភិបាលកិច្ច។

«ACCA បានផ្តល់ឲ្យខ្ញុំនូវទំនុកចិត្តដែលខ្ញុំត្រូវការដើម្បីដោះស្រាយរាល់បញ្ហាប្រឈមក្នុងអាជីព។ ខ្ញុំប្រាកដថាវានៅតែបន្តផ្តល់ឲ្យខ្ញុំនូវជំនាញចាំបាច់ដើម្បីជម្នះភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកលសម្រាប់អនាគតដ៏ល្អប្រសើរ»។

លោកដារិទ្ធ បន្ថែមថា៖ «វាក៏បានផ្តល់ឲ្យខ្ញុំនូវគុណសម្បត្តិ៣យ៉ាងដើម្បីក្លាយជាគណនេយ្យករអាជីពដែលមានការទទួលស្គាល់ខ្ពស់។ ACCA បានធ្វើឲ្យខ្ញុំក្លាយជាបុគ្គលដែលមានតម្លៃសម្រាប់ប្រទេសជាតិរបស់ខ្ញុំ ដោយផ្តល់ចំណេះដឹងបច្ចេកទេសទូលំទូលាយ ចំណេះដឹងភាសាអង់គ្លេសល្អ និងគុណតម្លៃនៃក្រមសីលធម៌វិជ្ជាជីវៈ»។

CamEd បានចូលជាសមាជិកសាកលវិទ្យាល័យផ្លូវការនៃ CFA Institute ដែលធ្វើឲ្យវាក្លាយជាស្ថាប័នគណនេយ្យ និងហិរញ្ញវត្ថុដ៏ល្អ និងល្បីល្បាញបំផុតមួយនៅក្នុងប្រទេសកម្ពុជា។

លក្ខណពិសេសរបស់វិទ្យាស្ថាន CamEd ត្រូវបានរៀបចំឡើងដើម្បីធានាថា និស្សិតដែលបញ្ចប់ការសិក្សាទាំងអស់នឹងទទួលបាននូវជំនាញ និងមានសមត្ថភាពពិតប្រាកដដែលមានតម្រូវការខ្ពស់នៅតាមស្ថាប័ន និងក្រុមហ៊ុននានា៕ ■

តមកពីទំព័រអក្សរ B

# ការអប់រំនៅពេលអនាគតនឹងផ្តោតកាន់...

**Q ក្នុងនាមជាអ្នកផ្តល់ការអប់រំ និងសហគ្រិនម៉ាឡេស៊ីឈានមុខគេ តើលោកមានយោបល់អ្វីខ្លះសម្រាប់ប្រទេសកម្ពុជា ដែលប្រជាជនយ៉ាងតិច៦៥ភាគរយ មានអាយុក្រោម ៣០ឆ្នាំ? តើពួកគេ គួរមានទិសដៅបែបណាទាក់ទងនឹងការអប់រំ ?**

កម្ពុជាអាចចាត់ទុកខ្លួនឯងថាមានសំណាង ដែលមានយុវជនច្រើនបែបនេះ។ ចង្អុលទៅអនាគត ដែលអាចបង្ហាញថា ជារ៉ែមាស សម្រាប់សេដ្ឋកិច្ច ប្រសិនបើទេពកោសល្យរបស់ពួកគេត្រូវបានបណ្តុះបណ្តាលបានត្រឹមត្រូវ។ ការចូលរួមរបស់ឧស្សាហកម្ម ត្រូវតែក្លាយជាអាទិភាពមួយនៅក្នុងការកែលម្អការអប់រំរបស់កម្ពុជា។ ឧស្សាហកម្ម គឺស្ថិតនៅជួរមុខនៃការផ្លាស់ប្តូរ ហើយពួកគេដឹងថា អនាគតស្ថិតនៅកន្លែងណា។ ពួកគេគ្មានជម្រើសក្រៅពីចាប់យកបច្ចេកវិទ្យាថ្មី ឬការអនុវត្តថ្មីៗដើម្បីរក្សាការប្រកួតប្រជែងនោះទេ។

ពួកគេដឹងពីជំនាញដែលពួកគេត្រូវការ ហើយតាមរយៈការចូលរួមរបស់ពួកគេ ប្រទេសកម្ពុជាអាចកសាងមូលធនមនុស្សដ៏ខ្លាំងក្លាមួយ ក្នុងនោះវានឹងទាក់ទាញវិនិយោគិនបរទេសកម្រិតខ្ពស់ឲ្យមកបង្កើតមូលដ្ឋានរបស់ពួកគេនៅកម្ពុជា។ ដូចប្រទេសម៉ាឡេស៊ីដែរ ប្រទេសកម្ពុជា គួរសម្លឹងទៅមុខ ដើម្បីលើកស្ទួយសេដ្ឋកិច្ចរបស់ខ្លួនឲ្យឈានដល់កម្រិតខ្ពស់ និងមូលធនមនុស្សដែលមានជំនាញខ្ពស់គឺជាផ្នែកមួយដ៏សំខាន់។



លោក លីម កុករីង ថ្លែងថាយុវជនចង់បានការសិក្សារបៀបអនុវត្តជាក់ស្តែង។

**Q ជាមួយនឹងការផ្ទុះឡើងជំងឺកូវីដ១៩ ពិភពអាជីវកម្មទាំងមូល និងសូម្បីតែវិស័យអប់រំក៏កំពុងមានការផ្លាស់ប្តូរចម្បងៗនៅក្នុងរបៀបដែលពួកគេធ្វើប្រតិបត្តិការនាពេលអនាគតដែរ។ តើលោកមើលឃើញគំរូនៃការផ្លាស់ប្តូរដ៏ធំនៅក្នុងរបៀបផ្តល់ការអប់រំនៅតាមសាលាមហាវិទ្យាល័យ និងសាកលវិទ្យាល័យដែរឬទេ ?**

ខ្ញុំគិតថាមនុស្សជំនាន់ថ្មីជាអ្នកដែលធ្វើឲ្យការអប់រំមានការផ្លាស់ប្តូរ។ ប៉ុន្តែរោគរាតត្បាតពេលនេះបានពន្លឿនការផ្លាស់ប្តូរកាន់តែលឿន។ យើងមានអ្វីដែលគេស្គាល់ថា មនុស្សជំនាន់ Z (Gen Z) ជាជំនាន់ដែលកើតឡើងចំសម័យអ៊ីនធឺណិត។ ពួកគេចាប់យកបច្ចេកវិទ្យាតាមរបៀបដែលគ្មានជំនាន់ណាធ្លាប់មាន។ ការផ្លាស់ប្តូរដោយកូវីដ១៩ មានមិនច្រើនទេដែលកំពុងបង្ខំឱ្យមានការផ្លាស់ប្តូរ។ ជំនាន់នេះដែលនឹងកំណត់របៀប និងអ្វីដែលពួកគេចង់រៀន។ ដូចខ្ញុំមើលឃើញ ការអប់រំនឹងផ្តោតលើជំនាញ និងទេពកោសល្យ។ យុវជនមិនចង់ចំណាយពេលច្រើនពេកលើការសិក្សាទ្រឹស្តីនោះទេ។ ពួកគេចង់បានការសិក្សារបៀបជាក់ស្តែង និងពីរបៀបដែលពួកគេទទួលបានព័ត៌មាន។

**Q និយោជកត្អូញត្អែរថា ស្ថាប័នធំៗមិនបានបង្កើតបេក្ខជនបានសមស្របសម្រាប់ទីផ្សារការងារដែលមានការផ្លាស់ប្តូរដ៏លឿននេះទេ។ តើស្ថាប័នអប់រំអាចដោះស្រាយបញ្ហានេះដោយរបៀបណាដើម្បីធ្វើឱ្យការងារកាន់តែប្រសើរឡើង និងបង្កើនផលិតភាពនៅកន្លែងធ្វើការ ?**

ចំណុចនេះ នាំខ្ញុំត្រឡប់ទៅកាន់ចម្លើយពីមុនវិញ គឺថា ឧស្សាហកម្មត្រូវតែមានការចូលរួមឲ្យបានខ្លាំងក្លាថា តើមនុស្ស ត្រូវបានទទួលការអប់រំ និងបណ្តុះបណ្តាលកម្រិតណា ? របៀបវាស់ស្ទង់ការសិក្សាត្រូវផ្លាស់ប្តូរ។ ប្រព័ន្ធបទប្បញ្ញត្តិត្រូវតែធ្វើការជាមួយឧស្សាហកម្ម ដើម្បីបង្កើតអ្វីដែលពិតជាចាំបាច់។

គ្រប់ស្ថាប័នទាំងអស់ ត្រូវតែគោរពតាមតម្រូវការនៃបទប្បញ្ញត្តិ ដូច្នេះការផ្លាស់ប្តូរពិតជាអាចកើតឡើងបានប្រសិនបើភាគីពាក់ព័ន្ធទាំងអស់អាចឯកភាពគ្នាលើវិធីសាស្ត្រដើម្បីវិនិច្ឆ័យពីសមត្ថភាព។ ជំនាញទន់ចាំបាច់ត្រូវផ្តល់ឱ្យកាន់តែមានសារៈសំខាន់។

សមត្ថភាពក្នុងការគិត និងដោះស្រាយបញ្ហាណាមួយគួរតែត្រូវបានគិតគូរឲ្យបានខ្លាំង។ យុវជនដឹងពីរបៀបទទួលជំនាញដែលពួកគេត្រូវការ ប៉ុន្តែភាគច្រើនពួកគេខ្វះជំនាញជីវិត។ ពួកគេមិនដឹងពីរបៀបដោះស្រាយបញ្ហាជីវិត។ តាមរយៈការដោះស្រាយភាពឆ្លាតវៃផ្នែកអារម្មណ៍របស់ពួកគេ យើងធ្វើឱ្យពួកគេមានទំនុកចិត្តជាមួយនឹងសមត្ថភាពក្នុងការដោះស្រាយភាពតានតឹង និងសម្ពាធការងារ។

ផលិតភាពនិងប្រសិទ្ធភាពអាចកើតឡើងបានលុះត្រាតែអ្នកធ្វើការងារនោះពេញចិត្តនឹងអ្វីដែលពួកគេកំពុងធ្វើ។ វាតម្រូវឱ្យមានការផ្លាស់ប្តូរគំរូក្នុងការអនុវត្តការគ្រប់គ្រង ដើម្បីចូលរួមក្នុងការបណ្តុះបណ្តាល ដើម្បីបង្កើនជំនាញនិយោជិតរបស់ពួកគេជំនួសឱ្យការផ្លាស់ប្តូរកម្លាំងពលកម្មមិនចាំបាច់ជាមួយនឹងបុគ្គលិកដែលមានជំនាញថ្មី៕ ■

# Invictus នាំយកការអប់រំប្រកបដោយគុណភាពខ្ពស់ជាមួយតម្លៃសមរម្យមកកាន់ទីក្រុងភ្នំពេញ

**ខណៈសាលារៀននៅកម្ពុជាកំពុងរៀបចំដំណើរការបើកឡើងវិញជាបណ្ដើរៗ លោក Clive Swale នាយកសាលាអន្តរជាតិ Invictus ភ្នំពេញ បានផ្ដល់បទសម្ភាស ជាមួយភ្នំពេញ ប៉ុស្ដិ៍ អំពីកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នដែលមានមូលដ្ឋាននៅប្រទេសសិង្ហបុរីមួយនេះ ក្នុងការនាំយកការអប់រំដែលមានគុណភាពខ្ពស់ តម្លៃសមរម្យ និងមានសុវត្ថិភាពមកកាន់ព្រះរាជាណាចក្រកម្ពុជា។**

**Q តើលោកអាចជម្រាបយើងបន្ថែមអំពីសាលាអន្តរជាតិ Invictus បានដែរឬទេ?**

សាលាអន្តរជាតិ Invictus បានខិតខំយ៉ាងខ្លាំងដើម្បីផ្ដល់នូវការអប់រំគុណភាពខ្ពស់ស្តង់ដាអន្តរជាតិជាមួយតម្លៃសមរម្យ នៅចំកណ្ដាលរាជធានីភ្នំពេញ។ ពីដំបូងយើងចាប់ផ្ដើមនៅប្រទេសសិង្ហបុរី ហើយសាលា Invictus បានអភិវឌ្ឍខ្លួនយ៉ាងឆាប់រហ័សជាសាលារៀនអន្តរជាតិឈានមុខគេមួយនៅសិង្ហបុរី ជាមួយនឹងលទ្ធផលដ៏ល្អប្រសើរ ដែលទទួលបាននៅក្នុងការវាយតម្លៃសាលា អន្តរជាតិ (ISA) កាលពីពេលថ្មីៗនេះ សម្រាប់សិស្សថ្នាក់ទី៣ និងទី៦ របស់យើង។

បច្ចុប្បន្ន សាលា Invictus មាន៦សាខានៅទូទាំងទ្វីបអាស៊ី ក្នុងនោះក៏មានកម្មវិធី «Invictus Family» ជាកម្មវិធីសិក្សាតាមអនឡាញលក្ខណៈអន្តរជាតិ ដែលអាចសិក្សាបាននៅទូទាំងទ្វីបអាស៊ី។

**Q តើអ្វីទៅដែលធ្វើឲ្យសាលា Invictus ពិសេសជាងសាលាអន្តរជាតិដទៃទៀតនៅក្នុងប្រទេសកម្ពុជា?**

សាលា Invictus គឺពិសេសប្លែកពីគេចំពោះការផ្ដល់ជូនកម្មវិធីសិក្សាអន្តរជាតិដែលមានភាពដ៏ទូលំទូលាយ លើសពីនេះគឺមានទីតាំងនៅចំកណ្ដាលរាជធានីភ្នំពេញ និងមានតម្លៃសមរម្យ។ យើងផ្ដល់ជូនការអប់រំចាប់ពីឆ្នាំទី១រហូតដល់ឆ្នាំទី១៣ ក្នុងនោះរួមមានមុខវិទ្យាគណិតវិទ្យាស្តង់ដាសិង្ហបុរីដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ក៏ដូចជម្រើសភាសា គឺយើងមានភាសាអង់គ្លេស/ចិន និងភាសាបារាំង។ ទាំងអស់នេះគឺមានតម្លៃសមរម្យ ឧទាហរណ៍យើងមិនគិតថ្លៃ capital fees ប្រចាំឆ្នាំ ដូចសាលាអន្តរជាតិដទៃទេ។

លើសពីនេះទៀត យើងផ្ដល់ឲ្យសិស្សរបស់យើងនូវ«ការផ្ទេរដោយគ្មានឧបសគ្គ»ទៅកាន់សាខារបស់យើងនៅសិង្ហបុរីនិងហុងកុងសម្រាប់កន្លែងទំនេរ និងផ្ដល់ទិដ្ឋាការដោយរដ្ឋាភិបាលមូលដ្ឋាន។ ចំណុចនេះធ្វើឱ្យសិស្សរបស់យើងអាចបន្តការសិក្សារបស់ពួកគេដោយគ្មានការរអាក់រអួល ប្រសិនបើឪពុកម្ដាយរបស់ពួកគេត្រូវផ្លាស់ទីលំនៅទៅកាន់ប្រទេសទាំងនោះ។

**Q តើលោកអាចរៀបរាប់អំពីផែនការបើកដំណើរការសាលា Invictus ភ្នំពេញ នៅខែសីហាបានដែរឬទេ?**

សាលាគ្រោងនឹងបើកសម្រាប់ឆ្នាំសិក្សាថ្មី ២០២០-២០២១ នៅក្នុងខែសីហា។ ការជួសជុលនិងកែលម្អកំពុងបន្តដំណើរការទៅយ៉ាងរលូន ទោះបីប្រឈមនឹងការពន្យារពេលខ្លះៗដោយសារបញ្ហាកូវីដ១៩ក្ដី ប៉ុន្តែសាលាយើងនឹងបើកដំណើរធម្មតាតាមការគ្រោងទុក។

បច្ចុប្បន្នមានភាពមិនច្បាស់លាស់មួយចំនួនចោទឡើងថា តើសាលាអន្តរជាតិនៅកម្ពុជាអាចបើកដំណើរការវិញជាធម្មតាបាននៅពេលណា? ប៉ុន្តែសាលា Invictus បានដាក់ពាក្យស្នើសុំការអនុញ្ញាតដើម្បីដំណើរការសាលារួចហើយ។ ក្នុងករណីដែលយើងមិនអាចបើកបាននៅក្នុងខែសីហាតាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាល នោះសាលាយើងនៅតែអនុវត្តការបង្រៀនតាមអនឡាញ ដែលជាវិធានការបណ្ដោះអាសន្ន។

**Q តើអ្វីជាវិធីសាស្ត្ររបស់សាលា Invictus នៅពេលនិយាយដល់ការបង្រៀនតាមអនឡាញ?**

វិធីសាស្ត្ររបស់យើងគឺធ្វើតាមរបៀបដែលយើងបង្រៀននៅក្នុងថ្នាក់រៀន។ នេះក៏ជាវិធីសាស្ត្រមួយសម្រាប់កម្មវិធី Invictus Family ដែរ និងដូចការបង្រៀននៅផ្ទះរបស់យើង។ លើសពីការបង្រៀនតាមអនឡាញដទៃទៀត យើងផ្ដល់ការបង្រៀន (បន្តផ្ទាល់) សម្រាប់កាលវិភាគភាគច្រើន។



លោក Clive Swale នាយកសាលាអន្តរជាតិ Invictus ភ្នំពេញ ។

វេទិកាជាច្រើនពឹងផ្អែកយ៉ាងខ្លាំងទៅលើការបង្រៀនតាម Asynchronous (តាមតម្រូវការ) ដែលដកចេញនូវការប្រាស្រ័យទាក់ទងផ្ទាល់តាមការផ្សាយបន្តផ្ទាល់ ដែលយើងគិតថាវាសំខាន់ណាស់។ យើងបានវិនិយោគលើវេទិកាបង្រៀន និងឧបករណ៍សិក្សា ដែលធ្វើឲ្យយើងផ្ដល់នូវបរិយាកាសនិងបទពិសោធសិក្សាដ៏ល្អសម្រាប់ទាំងសិស្ស និងគ្រូ។ ប៉ុន្តែម៉ោងសិក្សា និងមាតិកា គឺដូចគ្នា។

**Q តើលោកអាចប្រាប់ខ្ញុំអំពីការបញ្ចុះតម្លៃសម្រាប់ការចុះឈ្មោះដំបូង (Early Bird) បានទេ? តើថ្លៃបង់សាលាសម្រាប់កម្រិតបឋមសិក្សា និងមធ្យមសិក្សាមានចំនួនប៉ុន្មាន?**

តាមចំនួនកំណត់ សិស្សចុះឈ្មោះចូលរៀន១០០នាក់ដំបូងសម្រាប់ថ្នាក់បឋមសិក្សានៅរាជធានីភ្នំពេញ យើងផ្ដល់ការបញ្ចុះតម្លៃពិសេសត្រឹមតែ ៥ ០០០ដុល្លារប៉ុណ្ណោះក្នុង១ឆ្នាំ ហើយសិស្ស៥០នាក់ដំបូងដែលចុះឈ្មោះចូលរៀនសម្រាប់ថ្នាក់អនុវិទ្យាល័យយើងបញ្ចុះតម្លៃមកនៅត្រឹម ៥៥០០ដុល្លារប៉ុណ្ណោះក្នុង១ឆ្នាំ។ តម្លៃពិសេសនេះគឺសម្រាប់តែឆ្នាំសិក្សា ២០២០-២០២១ និង២០២១-២០២២ ប៉ុណ្ណោះ ចំពោះតម្លៃធម្មតារបស់យើងគឺ៨០០០ដុល្លារក្នុង១ឆ្នាំ។

**Q តើលោកផ្ដល់អ្វីខ្លះសម្រាប់ថ្នាក់បឋមសិក្សា និងអនុវិទ្យាល័យ?**

សម្រាប់ថ្នាក់បឋមសិក្សាយើងផ្ដល់កម្មវិធីសិក្សាថ្នាក់បឋមសិក្សាអន្តរជាតិ (IPC)។ IPC ប្រកាន់យកវិធីសាស្ត្រសកល ដែលមានគោលដៅសិក្សាជាក់លាក់លើគ្រប់មុខវិជ្ជាទាំងអស់ សម្រាប់ការសិក្សាផ្ទាល់ខ្លួន និងសម្រាប់ទស្សនៈលក្ខណៈអន្តរជាតិ។ វាផ្អែកលើកម្មវិធីសិក្សាជាតិរបស់ចក្រភពអង់គ្លេស រួមបញ្ចូលជាមួយគណិតវិទ្យាស្តង់ដាសិង្ហបុរី។

ទិដ្ឋភាពពិសេសមួយទៀតដែលយើងបានណែនាំគឺឱកាសសម្រាប់សិស្សក្នុងការជ្រើសរើស ភាសាចិនឬភាសាបារាំង ជាភាសាទី២ ហើយភាសាខ្មែរជាជម្រើសទី៣ សម្រាប់សិស្ស។ នៅកម្រិតអនុវិទ្យាល័យយើងនឹងប្រើប្រាស់កម្មវិធីសិក្សាខេមប្រ៊ីដអន្តរជាតិ។ នៅឆ្នាំទី៩ សិស្សនឹងទទួលការវាយតម្លៃ ខេមប្រ៊ីដ មុនពេលផ្លាស់ទៅខេមប្រ៊ីដ IGCSE (កំរិត O) ហើយចុងក្រោយខេមប្រ៊ីដកម្រិត A។

**Q តើសាលាដ៏ជោគជ័យរបស់លោកនៅប្រទេសសិង្ហបុរីនិងហុងកុង សម្របខ្លួនដូចម្ដេចចំពោះវិបត្តិកូវីដ១៩ដែលមិនធ្លាប់មាននេះ?**

សាលារៀនរបស់យើងនៅសិង្ហបុរីនិងហុងកុងត្រូវបានបិទទ្វារ ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩។ ប៉ុន្តែយើងបានសម្របខ្លួនទៅនឹងស្ថានការណ៍នេះបានយ៉ាងឆាប់រហ័ស ដោយប្ដូរទៅបង្រៀនតាមអនឡាញវិញដើម្បីធានាបាននូវការបន្តការសិក្សាសម្រាប់សិស្សរបស់យើង។ លើសពីនេះទៀត យើងអនុវត្តតាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាលក្នុងតំបន់យ៉ាងតឹងរ៉ឹងដើម្បីធានាឱ្យបាននូវការបើកសាលាឡើងវិញដែលមានសុវត្ថិភាព និងដោយរលូន។

**Q តើលោកទំទាក់ទំនងជាមួយសិស្សនិងឪពុកម្ដាយក្នុងពេលនេះយ៉ាងដូចម្ដេច?**

យើងភ្ជាប់ទំនាក់ទំនងជាមួយឪពុកម្ដាយនិងសិស្សតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងភាពជាដៃគូយុទ្ធសាស្ត្រ ក៏ដូចជាព្រឹត្តិការណ៍នានានៅក្នុងរាជធានីភ្នំពេញ។

**Q តើលោកមានសុទិដ្ឋិនិយមបែបណាសម្រាប់អនាគតរយៈពេលខ្លី មធ្យម និងវែង?**

Invictus មានន័យថា«អង់អាច» ហើយការរំខានពីការផ្ទុះឡើងនៃជំងឺកូវីដ១៩ កាន់តែជួយពង្រឹងបេសកកម្មរបស់យើងក្នុងការផ្ដល់ការអប់រំប្រកបដោយគុណភាព និងតម្លៃសមរម្យនៅក្នុងទីក្រុងភ្នំពេញ។ វិធីសាស្ត្របង្រៀនរបស់យើងគឺតាមរបៀបច្នៃប្រឌិត និងលើកទឹកចិត្តឲ្យសិស្សក្លាយជាអ្នកសិក្សាពេញ១ជីវិត ដែលរួមចំណែកជាវិជ្ជមានសម្រាប់ថ្ងៃអនាគត។

វិធីសាស្ត្រនេះជំរុញឱ្យយើងវិវឌ្ឍ និងសម្របខ្លួននៅក្នុងគ្រាដ៏លំបាកទាំងនេះ ដោយមានជំនួយ និងការលះបង់ពីគ្រូបង្រៀនរបស់យើង និងការប្រើប្រាស់បច្ចេកវិទ្យាទំនើប។

យើងជឿជាក់ថា ឪពុកម្ដាយដែលខ្វល់ខ្វាយពីអនាគតកូនចៅរបស់ពួកគេនឹងសម្លឹងឃើញសាលាអន្តរជាតិមួយនេះ ដែលមានទាំងគុណភាពស្តង់ដាអន្តរជាតិ និងតម្លៃសមរម្យ ដែលជាធម្មតាសម្រាប់សាលាដែលមានគុណភាពខ្ពស់ និងទីតាំងល្អគឺមានតម្លៃថ្លៃ។ ការអប់រំគឺជាការវិនិយោគរយៈពេលវែង។ ការប្ដេជ្ញាចិត្តឥតងាករេរបស់យើងក្នុងការផ្ដល់ការអប់រំគុណភាពស្តង់ដាអន្តរជាតិនឹងធានាបាននូវភាពជោគជ័យរបស់យើងរយៈពេលវែងនៅក្នុងប្រទេសកម្ពុជា៕ ■




សាលា Invictus មានទីតាំងស្ថិតនៅតាមបណ្ដោយមហាវិថីព្រះនរោត្តម។

**សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅគេហទំព័ររបស់យើង**
www.invictus.com.kh **ឬទូរស័ព្ទ**
**+៨៥៥ (០) ៩២២២២៨៦៨**